# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៤១.សសរ.....

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការចំរុះ ចុះបង្ក្រាបបទល្មើសព្រៃឈើ នៅតំបន់កន្ទុយនាគ ក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី

ɯɯ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩១/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ព្រៃឈើ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការចំរុះ ដើម្បីចុះធ្វើការបង្ក្រាបបទល្មើសព្រៃឈើ នៅតំបន់កន្ទុយនាគ ស្ថិតនៅក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគិរី ដែលមានសមាសភាពដូចខាងក្រោម:

| | | | | |
|---|---|---|---|---|
| ១- ឯកឧត្តម | ឆាន់ | សាផាន | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | ប្រធាន |
| ២- ឯកឧត្តម | ធុក | ក្រឿនវុទ្ធា | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | អនុប្រធាន |
| ៣- ឯកឧត្តម | អ៊ុក | សុខុន | អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |

៤- ឯកឧត្តម ឧត្តមសេនីយឯក **ខាំ នារា** នាយកទីចាត់ការកលយុត្ត និងជានាយរងសេនាធិការចំរុះ នៃអគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ សមាជិក

៥- ឯកឧត្តម ឧត្តមសេនីយទោ **ទន្សុ ពិសេន** មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

៦- ឯកឧត្តម ឧត្តមសេនីយទោ **ម៉ាន់ ណាយ** ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ សមាជិក

៧- ឯកឧត្តម **ឈរ ថាវណាត** អគ្គាធិការ ក្រសួងបរិស្ថាន សមាជិក

៨- លោក **មួង ម៉ៃយ** អភិបាលរងទី២ខេត្ត រតនៈគិរី សមាជិក

៩- លោក **ចាយ សាមិត្ត** ប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន សមាជិក

១០- លោក **មាស សុផល** ប្រធានតំរោងជីវចំរុះ និងតំបន់ការពារធម្មជាតិ នាយកដ្ឋានការពារ-អភិរក្សធម្មជាតិ ក្រសួងបរិស្ថាន សមាជិកអចិន្ត្រៃយ៍

**ប្រការ២.-**

គណៈកម្មការចំរុះនេះមានតួនាទី និងភារកិច្ច ដូចតទៅ :

១- ចុះទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ព្រៃឈើ នាំចេញខុសច្បាប់ និងប្រមូលវត្ថុតាងជាក់ស្តែងទុកនៅនឹងកន្លែងឱ្យបានសំរេចទាន់ពេលវេលា

២- ស្រាវជ្រាវរកអ្នកដែលពាក់ព័ន្ធ នឹងសកម្មភាពកាប់ និងនាំចេញឈើល្មើសច្បាប់នេះ

៣- សហការជាមួយភាគីឡាវ និងវៀតណាម ដើម្បីចុះកិច្ចសហប្រតិបត្តិការរួមក្នុងការចុះទប់ស្កាត់ បង្ក្រាបបទល្មើស និងស្រាវជ្រាវរកអ្នកពាក់ព័ន្ធនឹងបទល្មើសនេះ

៤- បូកសរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការចុះបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ខេត្តរតនៈគិរី

៥- រៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការ

**ប្រការ៣.-**

សមាជិកគណៈកម្មការចំរុះនេះ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តន៏ភារកិច្ចខាងលើឱ្យមានប្រសិទ្ធភាព និងចូលរួមប្រជុំការងារតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ។

**ប្រការ៤.-**

គណៈកម្មការចំរុះនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយតាមការចាំបាច់ ដែលមានសមាភាពមកពីក្រសួង ស្ថាប័នពាក់ព័ន្ធចូលរួម និងស្នើសុំកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទចូលរួមជាកម្លាំងក្នុងពេលចុះបេសកកម្ម។

**ប្រការ៥.-**

គណៈកម្មការចំរុះនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅក្រសួងបរិស្ថាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ដើម្បីអនុវត្តភារកិច្ច និងសំរួលការងាររបស់ខ្លួន។

**ប្រការ៦.-**

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលឈរជើងក្នុងតំបន់នោះ ត្រូវសហការ ចូលរួមធ្វើអន្តរាគមន៍ និងបង្កលក្ខណៈងាយស្រួល ដល់គណៈកម្មការចំរុះ ក្នុងការចុះអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានជោគជ័យ ។

**ប្រការ៧.-**

រាល់ការចំណាយលើបេសកកម្មចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគនេះ ជាបន្ទុករបស់ក្រសួងបរិស្ថាន ។

**ប្រការ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អភិបាលខេត្តរតនៈគីរី និងសមាសភាពដូចមានចែង ក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

*កន្លែងទទួល:*

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ៦ និងប្រការ៨
- ឯកសារ-កាលប្បវត្តិ